# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា







ចាប់ពីថ្ងៃទី ០២ ដល់ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៥ **ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម** និងជា**រដ្ឋមន្ត្រី**ទទួលបន្ទុកផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ានបានដឹកនាំគណៈប្រតិភូកម្ពុជាទៅចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅទីក្រុងវៀងចន្ទ នៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ អមដំណើរដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី** មាន **ឯកឧត្តមបណ្ឌិត ទឹង ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់កិច្ចសហ

ប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា **ឯកឧត្តមបណ្ឌិត ទូច វិសាលសុខ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងមន្ត្រីជំនាញរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមន្ត្រីជំនាញមកពីក្រសួងពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។



គោលបំណងនៃកិច្ចប្រជុំបានផ្តោតសំខាន់ទៅលើការត្រួតពិនិត្យ និងការវាយតម្លៃនៃការអនុវត្តការងារកន្លងមករបស់អនុគណៈកម្មាធិការជំនាញ និងគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីដាក់ជូនកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ជ្រាប និងអនុម័ត លើកិច្ចការដែលត្រូវអនុវត្តបន្ត និងកម្មវិធីផ្តួចផ្តើមថ្មីៗពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន។

**វិស័យសំខាន់ៗពាក់ព័ន្ធនឹងការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ានរួមមាន៖**

- អភិវឌ្ឍធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ថាមពលធម្មតា និងថាមពលកកើតឡើង
- បច្ចេកវិទ្យាចំណីអាហារ
- វិទ្យាសាស្ត្រលំហរសមុទ្រ
- ប្រព័ន្ធលំហរអាកាស
- ឧត្តុនិយម និងភូគព្ភសាស្ត្រ
- សម្ភារៈវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ជីវបច្ចេកវិទ្យា
- ព័ត៌មានវិទ្យា និងទូរគមនាគមន៍
- មាត្រាសាស្ត្រ

**កម្មវិធីសំខាន់ៗដែលបានលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំរួមមាន៖**

- ផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ២០១៦-២០២៥
- ពិនិត្យទៅលើថវិកាផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍
- ការបង្កើតមណ្ឌលចល័តធនធានមនុស្សផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍
- ការបង្កើតមជ្ឈមណ្ឌលនវានុវត្តន៍អាស៊ាន កូរ៉េ
- សហប្រតិបត្តិរវាងអាស៊ាន និងដៃគូសន្ទនា ផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ មានដូចជា៖
  - សហប្រតិបត្តិការអាស៊ាន ជប៉ុន
  - សហប្រតិបត្តិការអាស៊ាន សហរដ្ឋអាមេរិក
  - សហប្រតិបត្តិការអាស៊ាន រុស្ស៊ី
  - សហប្រតិបត្តិការអាស៊ាន កូរ៉េ
  - សហប្រតិបត្តិការអាស៊ាន អឺរ៉ុប

**ជាលទ្ធផលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្រ្តីដូចខាងក្រោម៖**



**១.អង្គប្រជុំបានសម្រេចអនុម័តទៅលើការងារដូចខាងក្រោម៖**

- ផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ២០១៦-២០២៥
- មណ្ឌលចល័តធនធានមនុស្សផ្នែកវិទ្យាសាស្រ្ត និងបច្ចេកវិទ្យាអាស៊ាន

**២.អង្គប្រជុំបានកត់សម្គាល់ទៅលើការងារដូចខាងក្រោម៖**

- របាយការណ៍សកម្មភាពអនុវត្តការងារកន្លងមក និង
- កម្មវិធីផ្តួចផ្តើមថ្មីដែលត្រូវអនុវត្តបន្តរបស់អនុគណៈកម្មាធិការជំនាញ




ចំនុចដែលគួរឱ្យកត់សម្គាល់សម្រាប់ផលប្រយោជន៍ និងជាកិត្តិយសដល់ប្រទេសកម្ពុជាយើងគឺ យើងបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដោយភាគីទាំងពីរយល់ព្រមអនុវត្តតាមកម្មវិធីខាងក្រោម៖

១.ការផ្លាស់ប្តូរទស្សនៈកិច្ចរបស់ប្រតិភូនៃប្រទេសទាំងពីរយ៉ាងហោចណាស់ម្តងក្នុង១ឆ្នាំ

២.ការផ្លាស់ប្តូរព័ត៌មាន និងឯកសារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទៅវិញទៅមក

៣.សហការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំដើម្បីជំរុញការអភិវឌ្ឍ និងការបង្កើនចំណេះដឹងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅក្នុងប្រទេសទាំងពីរ

៤.សហការរៀបចំគម្រោងសិក្សាស្រាវជ្រាវរួមគ្នា ឬតាមទម្រង់សកម្មភាពផ្សេងៗពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រោមក្របខណ្ឌវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍អាស៊ាន និងតំបន់ផ្សេងៗ

៥.សហការគ្នាក្រោមទម្រង់សហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមការឯកភាពគ្នាខាងលើ

តាមតារាងប្រទេសជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ កម្ពុជានឹងដល់វេនធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រៅផ្លូវការថ្នាក់រដ្ឋមន្ត្រីអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា កិច្ចប្រជុំគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងកិច្ចប្រជុំពាក់ព័ន្ធ ដែលនឹងប្រព្រឹត្តិទៅនាខែតុលា ឆ្នាំ២០១៦។